# កាលប្បវត្តិព្រឹត្តិការណ៍កូដកម្មណាហ្គាវើលដ៍

## ពីខែមីនា ដល់ ខែមេសា ឆ្នាំ២០២២

ក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍បានបញ្ឈប់បុគ្គលិក កម្មករ និយោជិត ពីការងារក្នុងទ្រង់ទ្រាយធំកាលពីខែមេសា ឆ្នាំ២០២១ ហើយបានរងការចោទប្រកាន់ថាបាន**រំលោភបំពានសិទ្ធិការងារ និងសិទ្ធិសហជីព** ដែលនាំឱ្យបុគ្គលិក កម្មករ និយោជិតជាច្រើនរយនាក់តវ៉ាការបញ្ឈប់ការងារនេះ។ បុគ្គលិក និងសមាជិកនៃសហជីពទ្រទ្រង់សិទ្ធិការងារបុគ្គលិកកម្មករខ្មែរនៃក្រុមហ៊ុនណាហ្គាវើលដ៍ («សហជីពទ្រទ្រង់សិទ្ធិការងារ») បានចាប់ផ្តើមធ្វើកូដកម្មដោយសន្តិវិធីនៅពាក់កណ្តាលខែធ្នូ ដើម្បីទាមទារ**ដំណោះស្រាយសមរម្យចំពោះវិវាទការងារ** ក្នុងនោះរួមទាំងការទាមទារឱ្យមានការទទួលយកបុគ្គលិកចូលបម្រើការងារវិញ និងសំណងសមរម្យសម្រាប់អតីតបុគ្គលិក ព្រមទាំងឱ្យក្រុមហ៊ុនណាហ្គាវើលដ៍ **គោរពសិទ្ធិរបស់និយោជិត និងច្បាប់ការងារឱ្យបានប្រសើរ។**




កាលប្បវត្តិខាងក្រោមនេះចង់ក្រងបន្ថែមលើកាលប្បវត្តិពីមុន និងលើកឡើងពីទិដ្ឋភាពនៃព្រឹត្តិការណ៍សំខាន់ៗមួយចំនួនទាក់ទងនឹងកូដកម្មដែលកំពុងបន្តកើតមានឡើងនៅណាហ្គាវើលដ៍ចាប់តាំងពី**ខែមីនាដល់ខែមេសាឆ្នាំ២០២២**។ កូដកម្មនេះបានបន្តប្រព្រឹត្តទៅដោយប្រឈមនឹងការរំលោភបំពានសិទ្ធិ និងការមិនបោះបង់ការប្តេជ្ញាចិត្តរបស់កូដករក្នុង**ការតស៊ូមតិដើម្បីសិទ្ធិការងារ**រហូតស្វែករកបានដំណោះស្រាយសមស្រប។

## ខែមីនា ឆ្នាំ២០២២

**១០**

សាលាឧទ្ធរណ៍រាជធានីភ្នំពេញបាន**បដិសេធសំណើសុំនៅក្រៅឃុំ**របស់**តំណាងសហជីពចំនួន៨នាក់**ដែលជាប់ឃុំចាប់តាំងពីខែមករា ឆ្នាំ២០២២។ បន្ទាប់ពី**ជាប់ឃុំអស់រយៈពេល ៧០ ថ្ងៃ** តុលាការបាន**ដោះលែងថ្នាក់ដឹកនាំសហជីព៨រូបឱ្យនៅក្រៅឃុំជាបណ្តោះអាសន្ន** នៅថ្ងៃទី១៤ និងថ្ងៃទី១៧ ខែមីនា តាមការអន្តរាគមរបស់រដ្ឋាភិបាលដើម្បីអនុញ្ញាតឱ្យបន្តកិច្ចចរចា។

បន្ទាប់ពីសម្រាកមួយរយៈដោយសារការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ កូដករណាហ្គាវើលដ៍ចំនួន១៥៦ នាក់បាន**ព្យាយាមបន្តធ្វើកូដកម្មដោយសន្តិវិធី**នៅខាងមុខអគារណាហ្គាវើលដ៍។ អាជ្ញាធរបានដាក់ពង្រាយកម្លាំងសន្តិសុខដើម្បីស្ទាក់រារាំងកូដករ និងបាន**រុញច្រានពួកគេបញ្ចូលទៅក្នុងរថយន្តក្រុង** ហើយបានដឹកពួកគេទៅកាន់មណ្ឌលចត្តាឡីស័កនៅព្រែកព្នៅ។ អាជ្ញាធរបានអនុញ្ញាតឱ្យកូដករទាំងនោះចាកចេញពីមណ្ឌលចត្តាឡីស័កនៅរសៀលថ្ងៃដដែលនោះ។ មានការរាយការណ៍ថាមានកូដករជាច្រើននាក់**រងរបួស**ដោយសារ**នគរបាលប្រើអំពើហិង្សា**។ ស្រដៀងគ្នានេះចាប់ពីថ្ងៃទី១៣ ដល់ទី១៧ ខែមីនា កូដករណាហ្គាវើលដ៍ជាច្រើនរយនាក់បានបន្តប្រមូលផ្តុំគ្នានៅខាងមុខអគារកាស៊ីណូណាហ្គាវើលដ៍និងបានប្រឈមជាមួយនឹងកម្លាំងសន្តិសុខ។ មានការរាយការណ៍ថាអាជ្ញាធរបាន**វាយដំ ដាល់ និងអូសទាញកូដករ** ក្នុងនោះរួមទាំងស្ត្រីមានផ្ទៃពោះផងដែរបញ្ចូលទៅក្នុងរថយន្តក្រុងមុនពេលដឹកពួកគេទៅកាន់មណ្ឌលចត្តាឡីស័ក។





**១៤**

នៅថ្ងៃទី១៤ ខែមីនា **ក្រសួងការងារបានទទួលស្គាល់សហជីពដែលទើបបង្កើតថ្មី** នៅក្រុមហ៊ុនណាហ្គាវើលដ៍ ដែលត្រូវបានកូដករយល់ថាជាមធ្យោបាយដើម្បីធ្វើឱ្យ**ប៉ះពាល់**សិទ្ធិរបស់ពួកគេ និងបញ្ច្រាបឥទ្ធិពល។ នៅថ្ងៃទី១៦ ខែមីនា រដ្ឋាភិបាលបានចេញ**សេចក្តីប្រកាសព័ត៌មាន**បង្គាប់ឱ្យកូដករបញ្ឈប់ធ្វើកូដកម្មក្រោមហេតុផលនៃការឆ្លងរាតត្បាតនៃជំងឺកូវីដ-១៩ព្រមទាំង**ព្រមានកូដករ**ថាពួកគេបានបំពានបម្រាមរបស់រដ្ឋាភិបាលក្នុងការទប់ស្កាត់ការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលអាចនឹងប្រឈមនឹងការយកពួកគេចេញពីកន្លែងកូដកម្មដោយសន្តិវិធី និង**ប្រឈមនឹងការបាត់បង់អត្ថប្រយោជន៍**ប្រសិនបើពួកគេនៅតែបន្តធ្វើកូដកម្ម។

**១៦**

**ការបន្តកិច្ចចរចារ**វាងក្រុមហ៊ុនណាហ្គាវើលដ៍ ថ្នាក់ដឹកនាំសហជីពទ្រទ្រង់សិទ្ធិការងារ និងក្រសួងការងារ ប៉ុន្តែ**ពុំទទួលបានលទ្ធផលផ្លែផ្កា**។ ដំណាលគ្នានោះកូដករជាច្រើនរយនាក់បានបន្តព្យាយាមធ្វើការប្រមូលផ្តុំគ្នា ហើយជាថ្មីម្តងទៀតពួកគេត្រូវបានអាជ្ញាធររុញច្រានបញ្ចូលទៅក្នុងរថយន្តក្រុងជាច្រើនគ្រឿង។ លើកនេះអាជ្ញាធរបានដឹកពួកគេទៅកាន់**ទីលានប្រជាធិបតេយ្យ**ស្ថិតនៅជាយរាជធានីភ្នំពេញ និងបាន**ទុកពួកគេចោលក្នុងរថយន្តក្រុងជាច្រើនម៉ោង**មុនពេលអនុញ្ញាតឱ្យចាកចេញនៅពេលយប់។

**១៨**

ថ្នាក់ដឹកនាំសហជីពទ្រទ្រង់សិទ្ធិការងារ និងតំណាងក្រុមហ៊ុនបានជួបប្រជុំជា**លើកទីពីរ**ដើម្បីបន្តកិច្ចចរចាដើម្បីដោះស្រាយវិវាទការងារដែលអូសបន្លាយនោះ។ ក្រោយមកថ្នាក់ដឹកនាំសហជីពបាន**សម្តែងការខកចិត្ត**ចំពោះក្រុមហ៊ុនដោយសារមិនបាន**លើកឡើងកម្មវត្ថុតាមការទាមទាររបស់ពួកគេ** និងប្រកាន់ជំហរផ្តល់សំណងដូចពីខាងដើមដដែល។

**២១**

ចាប់ពីថ្ងៃទី២០ ដល់ទី៣១ ខែមីនា កូដករណាហ្គាវើលដ៍បានបន្តប្រមូលផ្តុំគ្នាសឹងតែរាល់ថ្ងៃដើម្បីបន្តធ្វើកូដកម្មដោយសន្តិវិធី ប៉ុន្តែតែងតែត្រូវបានអាជ្ញាធររារាំង។ ពួកគេបានបន្ត**ប្រឈមនឹងការប្រើអំពើហិង្សា ការរុញច្រានបញ្ចូលទៅក្នុងរថយន្តក្រុង**ពីសំណាក់អាជ្ញាធរ និង**ត្រូវបានដឹកយកទៅឆ្ងាយ**ពីអគារកាស៊ីណូណាហ្គាវើលដ៍។









២២

នៅថ្ងៃទី២២ ខែមីនា តំណាងសហជីពទ្រទ្រង់សិទ្ធិការងារ បានលើកឡើងថា **ពួកគេនឹងធ្វើពហិកាចូលរួមកិច្ចប្រជុំនៅជុំទី៣** ព្រោះក្រុមហ៊ុនណាហ្គាវើលដ៍បដិសេធពិចារណាទទួលយកតាមការទាមទាររបស់ខ្លួន។

២៣

នៅថ្ងៃទី២៣ ខែមីនា ថ្នាក់ដឹកនាំសហជីពបួនរូបឈប់ចូលរួមកិច្ចប្រជុំជាមួយភាគីក្រុមហ៊ុនណាហ្គាវើលដ៍ និងក្រសួងការងារ។ ប៉ុន្តែនៅក្នុងកិច្ចប្រជុំនាពេលនោះ**ពុំមានវត្តមាន កញ្ញា ឈឹម ស៊ីថរ** ប្រធានសហជីពទ្រទ្រង់សិទ្ធិការងារចូលរួមឡើយ។ សមាជិកសហជីពភាគច្រើនបានបោះឆ្នោតជំទាស់នឹងការបន្តការចរចា ព្រោះភាគីក្រុមហ៊ុន និងក្រសួងការងារពុំមានឆន្ទៈពិភាក្សាលើការទទួលយកបុគ្គលិក កម្មករនិយោជិតដែលត្រូវបានបញ្ឈប់ពីការងារឱ្យចូលបម្រើការងារវិញឡើយ។

២៤

បន្ទាប់ពីកូដករចេញសេចក្ដីថ្លែងការណ៍លើបណ្ដាញផ្សព្វផ្សាយសង្គមរិះគន់ពីការប្រើកម្លាំងហួសប្រមាណរបស់អាជ្ញាធរនៅពេលរុញច្រានកូដករចូលទៅក្នុងរថយន្តក្រុង សាលារាជធានីភ្នំពេញបានចេញ**សេចក្តីប្រកាសព័ត៌មាន**ឆ្លើយបំភ្លឺថារូបភាព និងវីដេអូ នៃការប្រើអំពើហិង្សារបស់នគរបាលលើកូដករដែលត្រូវបានចែកចាយលើបណ្ដាញផ្សព្វផ្សាយសង្គមនោះគឺជា **«ព័ត៌មានក្លែងក្លាយ»**។ សេចក្ដីថ្លែងការណ៍នោះព្រមទាំងបាន**បង្អាប់បង្អោន**កូដករជាស្ត្រីថាមានឥរិយាបថ **«មិនសមជាស្ត្រីខ្មែរ»** ព្រមទាំងបាន**ចោទប្រកាន់កូដករ**ថាជា**អ្នកញុះញង់ឱ្យមានអំពើហិង្សា**ទៀតផង។

២៩

**កិច្ចចរចាលើកទីបួន**រវាងក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍ ថ្នាក់ដឹកនាំសហជីពទ្រទ្រង់សិទ្ធិការងារ និងក្រសួងការងារបានបន្ត **តែពុំទទួលបានលទ្ធផល**។

## ខែមេសា ឆ្នាំ២០២២

១

នៅថ្ងៃទី១ ខែមេសា កូដករណាហ្គាវើលដ៍ចំនួន១៥៨នាក់**ត្រូវបានរាំងខ្ទប់នឹងរនាំងផ្លូវ** ខណៈ**កម្លាំងសន្តិសុខមិនឱ្យពួកគាត់**បន្តកូដកម្មដោយសន្តិវិធី។ **អ្នកឃ្លាំមើលសិទ្ធិមនុស្ស**និង**អ្នកសង្កេតការណ៍**ត្រូវបាន**បញ្ជាឱ្យនៅឆ្ងាយពីទីតាំងកូដកម្ម**។

២

នៅថ្ងៃបន្ទាប់ អាជ្ញាធរ និងក្រុមសន្តិសុខស្លៀកពាក់ឯកសណ្ឋានស៊ីវិលបន្តបង្ខំកូដករចំនួន១៣៥នាក់ឱ្យឡើងឡាន ដើម្បីបង្ការពួកគាត់ក្នុងការជួបជុំនៅក្រៅអគារក្រុមហ៊ុន។ **ក្រុមកូដករត្រូវបាននាំចេញយ៉ាងឆ្ងាយពីបរិវេណអាគារកាស៊ីណូ** និងត្រូវបានបញ្ជូនទៅទីលានប្រជាធិបតេយ្យ។ កូដករជាច្រើនរូបបានរាយការណ៍ ពី**ការឈឺចាប់លើរាងកាយ** និងមានស្នាមរបួសនៅលើដងខ្លួនដោយសារតែ**ការប្រើកម្លាំងពីអាជ្ញាធរ**។

៤

សកម្មជន៥នាក់ មកពី**ក្រុមយុវជនខ្មែរថាវរៈ** បាន**ដាក់ញត្តិ**ទៅ**ក្រសួងមហាផ្ទៃ** និង**ក្រសួងកិច្ចការនារី** ដើម្បីឱ្យក្រសួងទាំងពីរនេះធ្វើអន្តរាគមន៍ដោះស្រាយអំពើហិង្សា និង**ការបៀតបៀនផ្លូវភេទ**ពីសំណាក់អាជ្ញាធរមកលើកូដករជាស្ត្រី។






៦

**ការចរចារមួយលើកទៀតបានធ្វើឡើង** តែពុំទទួលបានលទ្ធផលអ្វីឡើយ។ ក្រុមហ៊ុនកាស៊ីណូណាហ្គាវើលដ៍បន្តរក្សាជំហររបស់ខ្លួន និងបដិសេធការទាមទាររបស់សហជីពទ្រទ្រង់សិទ្ធិការងារ ឱ្យទទួលកម្មករ២០០នាក់ចូលមកធ្វើការវិញ ដែលរួមមានសមាជិកសហជីពជាន់ខ្ពស់ ។

៨

កូដករចំនួន ១១៩នាក់ ព្យាយាមជួបជុំដោយសន្តិវិធីជាថ្មីម្តងទៀតនៅក្រៅអាគារកាស៊ីណូណាហ្គាវើលដ៍។ **អាជ្ញាធររដ្ឋបាលរាជធានីភ្នំពេញជាច្រើននាក់ត្រូវបានពង្រាយ** ដើម្បីបង្ការកូដកម្មនៅក្រៅអាគារកាស៊ីណូ ដោយកូដករត្រូវបាន**រុញឱ្យឡើងឡានក្រុងដែលកំពុងចតចាំជាស្រេច**។ កូដករត្រូវបានដឹកទៅជាយរាជធានី និងត្រូវបានឱ្យចុះពីឡាននៅទីលានប្រជាធិបតេយ្យបន្ទាប់ពីប៉ុន្មានម៉ោងក្រោយមក។

១៩ ២០ ២១

បន្ទាប់ពីសម្រាករយៈពេល៩ថ្ងៃដើម្បីប្រារព្ធពិធីបុណ្យចូលឆ្នាំខ្មែរ និងដោយសារការចចារបរាជ័យជាច្រើនលើក កូដករណាហ្គាវើលដ៍ចំនួន១០៦នាក់បានជួបជុំគ្នានៅមុខអាគារកាស៊ីណូ ក្នុងបំណង**ព្យាយាមបន្តកូដកម្មដោយសន្តិវិធី**។ នាពេលរសៀលបន្តិចក្រោយពេលពួកគេទៅដល់មុខស្ថានទូតអូស្រ្តាលី កូដករត្រូវបាន**រុញដោយហិង្សា**ឱ្យឡើងឡានក្រុង និងត្រូវបានដឹកទៅសួនសត្វនៅជ្រោយចង្វារ ជាយរាជធានីភ្នំពេញ មុននឹងត្រូវបានឱ្យចុះពីឡាននៅទីលានប្រជាធិបតេយ្យប៉ុន្មានម៉ោងក្រោយមក។ នៅថ្ងៃទី២០ កូដករចំនួន១១៩នាក់ ហើយនៅថ្ងៃទី២១ កូដករចំនួន១៣៦នាក់ ត្រូវបានអាជ្ញាធរ**រារាំង**ក្នុងការធ្វើកូដកម្មតាមរបៀបដូចខាងលើ។

២៥

**ការចចារលើកទីប្រាំមួយ**ត្រូវបានធ្វើឡើងរវាងក្រុមហ៊ុនណាហ្គាវើលដ៍ ថ្នាក់ដឹកនាំសហជីពទ្រទ្រង់សិទ្ធិការងារ និងក្រសួងការងារ។ ថ្នាក់ដឹកនាំសហជីព បន្តទាមទារឱ្យបញ្ចូលបុគ្គលិកចំនួន២០០នាក់ចូលធ្វើការវិញ **ដោយមិនទទួលបានជោគជ័យ**។

ពីថ្ងៃទី២៦ មេសា ដល់ ៣០ មេសា កូដករព្យាយាមបន្តកូដកម្មរបស់ខ្លួននៅមុខអាគារណាហ្គាវើលដ៍ ប៉ុន្តែត្រូវ**ប្រឈមជាមួយអាជ្ញាធរ** និង**នាំចេញពីមុខអគារកាស៊ីណូ**៕




## ខែឧសភា ឆ្នាំ២០២២

១

មកដល់**ថ្ងៃទិវាពលកម្មនេះ** វិវាទការងារណាហ្គាវើលដ៍នៅតែបន្ត**គ្មានដំណោះស្រាយ**។ រដ្ឋាភិបាលបន្តបដិសេធសិទ្ធិជាមូលដ្ឋានរបស់កូដករណាហ្គាវើលដ៍ក្នុងការធ្វើកូដកម្ម ដែលបង្កជាឧបសគ្គចំពោះកិច្ចខិតខំប្រឹងប្រែង**ទាមទារឱ្យមានការគោរពសិទ្ធការងារកាន់តែប្រសើរឡើង**។

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights
@CCHRCambodia
@CCHRCambodia
cchrcambodia.org
sithi.org
ខែឧសភា ឆ្នាំ២០២២
BY NC SA